វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សង្ខេបទស្សនវិស័យប្រទេសកម្ពុជា*

ឆ្នាំ២០១៣ លេខ ០១

## ការប្រមើលពីសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០១៣៖ លទ្ធភាព និង អាទិភាពគោលនយោបាយ ដើម្បីកំណើនមានចីរភាព និងសម្រាប់គ្រប់គ្នា[១]

"បច្ចុប្បន្ននេះ យើងកំពុងតែស្ថិតនៅចំណុចដ៏សំខាន់ក្នុងដំណើរការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា ដោយយើងកំពុងបន្តលើជោគជ័យកន្លងមក និងរំកិលបន្តិចម្តងៗ ឈានពីប្រទេសអភិវឌ្ឍន៍តិចតួចទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ - ២០១៦ ។"

*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*
*នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*

### សេដ្ឋកិច្ចសាកលឆ្នាំ២០១៣៖ ភាពជំពាក់ទាក់ទងនឹងកម្ពុជា

សេដ្ឋកិច្ចសាកល ហាក់មានសន្ទុះខ្លះឡើងវិញ និងមានស្ថិរភាពល្អគួរសម ។ លទ្ធភាពអាចកើតព្រឹត្តិការណ៍ហិរញ្ញវត្ថុធ្ងន់ធ្ងរក្នុងប្រទេសមានសេដ្ឋកិច្ចជឿនលឿនបានថយចុះជាបណ្តើរៗ វិស័យផលិតកម្ម កំពុងបង្ហាញសញ្ញារើបឡើងវិញ ហើយគ្រោះថ្នាក់នៃរដ្ឋនៅអឺរ៉ុបមិនអាចសងបំណុលរបស់ខ្លួនបាន ក៏បានថយចុះដែរ ។ ទោះបីមានសញ្ញាលើកទឹកចិត្តទាំងនេះក្តី ដំណើររើបសេដ្ឋកិច្ចមាំទាំ វាស្ថិតនៅឆ្ងាយខាងមុខ ហើយការប្រមើលជាទូទៅក៏នៅអាប់អួរនៅឡើយ៖ កំណើនទាបហាក់នៅតែជាលក្ខណៈដដែលមួយនៃសេដ្ឋកិច្ចប្រទេសជឿនលឿន ។

នៅទូទាំងអាស៊ីប្រទេសនានាកំពុងទទួលបានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ និងមានស្ថិរភាពល្អ លើកលែងករណីប្រទេសជប៉ុនដែលត្រូវធ្វើកំណែទម្រង់រចនាសម្ព័ន្ធយ៉ាងជ្រាលជ្រៅ ដើម្បីជំរុញសេដ្ឋកិច្ចឲ្យឆ្លងផុតពីស្ថានភាពជាប់គាំងរហូតមកនេះ ។ តម្រូវការពីខាងក្រៅជារួមកំពុងទទួលបានស្ថិរភាពខ្លះឡើងវិញ ហើយកំណើនលំហូរចូលមូលធនបានពីប័ណ្ណបំណុល និងប្រតិបត្តិការនៃទីផ្សារហិរញ្ញវត្ថុ វាបង្ហាញពីទំនុកចិត្តឡើងវិញទៅលើលទ្ធភាពមានកំណើន ។ ប៉ុន្តែមិនគួរធូររលុងនៅពេលនេះទេ៖ អ្នកធ្វើគោលនយោបាយត្រូវប្រយ័ត្នជានិច្ចចំពោះកំណើនលឿនបែកពពុះផ្នែកអចលនទ្រព្យ ហានិភ័យនៃអតិផរណា និងការរាលដាលនៃវិបត្តិសេដ្ឋកិច្ចនៅតំបន់អឺរ៉ុប ។

ទីផ្សារកំពុងផុសឡើងនានានៅអាស៊ី ដែលនាំមុខដោយប្រទេសចិនបានក្លាយជាកម្លាំងចម្បងជំរុញ កំណើនសេដ្ឋកិច្ចសាកល ដោយផ្តល់ឱកាសថ្មីៗដល់ពួកអ្នកធ្វើគោលនយោបាយក្នុងតំបន់ ។ ហើយព្រឹត្តិការណ៍ដ៏គួរចាប់អារម្មណ៍បំផុត គឺបណ្តាទីផ្សារទទួលឥទ្ធិពលពី ការឈានឡើងនៃប្រទេសចិនដែលជាមហាអំណាចមួយខាងសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយ ។

វត្តមានរបស់ចិននៅក្នុងតំបន់ កើនឡើងជាខ្លាំងក្នុងប៉ុន្មានឆ្នាំថ្មីៗ ហើយសព្វថ្ងៃបានក្លាយជាស្នូល នៃបណ្តាញផលិតកម្ម ដោយតភ្ជាប់សមាសភាគផ្សេងៗនៃដំណើរការផលិតកម្មក្នុងតំបន់ ជួយសម្រួលការផ្គត់ផ្គង់ទំនិញទៅទីផ្សារសាកល និងជាប្រភពសំខាន់មួយនៃវិនិយោគផ្ទាល់ពីបរទេស (FDI) ។ សេដ្ឋកិច្ចប្រទេសអាស៊ីជាប់ទាក់ទងគ្នាខ្លាំងណាស់ ជាពិសេសសម្រាប់មហាអនុតំបន់មេគង្គ (GMS) ហើយការផ្លាស់ប្តូរបន្តិចបន្តួចក្នុងកំណើន ផសស នៅចិន អាចមានផលប៉ះពាល់ខ្លាំងទៅលើសេដ្ឋកិច្ចនៅតាមប្រទេសនីមួយៗ ។

ប្រសិនបើសេដ្ឋកិច្ចប្រទេសចិនបន្តកើនឡើង ហើយសង្គមមនុស្សនៅចិនកាន់តែសម្បូរទ្រព្យធននោះ ទីផ្សារធំៗនឹងផុសឡើងសម្រាប់ផលិតផលផ្សេងៗរបស់ GMS ។ តម្រូវការផលិតផលកសិកម្ម និងទំនិញប្រើបានយូរ បាននិងកំពុងកើនឡើងជាខ្លាំង នៅពេលដែលលំនាំចំណាយប្រើប្រាស់របស់ប្រជាជនចិនមានការផ្លាស់ប្តូរ ។ ដើម្បីឲ្យការអភិវឌ្ឍឧស្សាហកម្មមានចីរភាព និងបានចម្រុះមុខ ចិនត្រូវការជាចាំបាច់នូវ វត្ថុធាតុដើមយ៉ាងច្រើនសន្ធឹកសន្ធាប់ ធនធានរ៉ែ និងថាមពល ហើយ GMS មានស្ថានភាពល្អទាំងផ្នែកភូមិសាស្ត្រ សេដ្ឋកិច្ច និងនយោបាយ ដើម្បីបំពេញតម្រូវការនេះ ។

ដោយសារថ្លៃពលកម្មនៅចិនបានកើនឡើងនោះ ឧស្សាហកម្មនឹងរំកិលទៅរកតំបន់ដែលមានថ្លៃដើមផលិតកម្មទាបជាង ។ ដោយមានថ្លៃពលកម្មទាប និងការបន្សុីខ្លួនកម្រិតខ្ពស់ទៅក្នុងបណ្តាញផលិតកម្មក្នុងតំបន់ មហាអនុតំបន់មេគង្គមានស្ថានភាពល្អដើម្បីទទួលយកតួនាទីជាមជ្ឈមណ្ឌលផលិតកម្មសាកល ។

---

[១] អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញក្នុងសន្និសីទទស្សនវិស័យប្រទេសកម្ពុជាឆ្នាំ២០១៣ បកស្រាយដោយ ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុប្រធានអចិន្ត្រៃយ៍នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, លោក Faisal Ahmad តំណាងជាន់ខ្ពស់នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំនៅកម្ពុជា, បណ្ឌិត Srinivasa Madhur ប្រធានផ្នែកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI និង លោក Mike Smith អគ្គនាយកក្រុមហ៊ុន Australia and New Zealand Banking Group Limited ( ANZ ) ។

* លទ្ធផលនៃសន្និសីទទស្សនវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៣
ក្នុងកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

បញ្ហាប្រឈមសម្រាប់អ្នកធ្វើគោលនយោបាយកម្ពុជា គឺការរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចឡើងវិញ ដើម្បីចាប់យកឱកាសល្អផុសចេញពីកំណើននៅចិន។ បើសិនប្រើប្រាស់បានសក្តិសិទ្ធិ ឧបករណ៍ផ្នែកគោលនយោបាយអាចទាញយកផលប្រយោជន៍ពី បម្រែបម្រួលលំនាំនៃលំហូរមូលធនក្នុងតំបន់ ដើម្បីបង្កើនការងារ បង្កើនផលិតភាពកម្លាំងពលកម្ម បង្កើនការផ្ទេរបច្ចេកវិទ្យា ឈានទៅផលិតទំនិញកាន់តែមានតម្លៃខ្ពស់ ហើយសម្រេចបានកំណើន ផសស ប្រកបដោយចីរភាព។

## កំណើនសេដ្ឋកិច្ចរឹងមាំ និងចម្រុះមុខនៅកម្ពុជា

កំណើនសេដ្ឋកិច្ចកម្ពុជា ដែលគេគន់គូរជាថ្មីដំឡើងដល់ ៧,៧% គឺនៅតែរឹងមាំក្នុងឆ្នាំ២០១២។ ការរីកចម្រើនកើតមាននៅគ្រប់ផ្នែក ហើយវិស័យស្នូលទាំងបីនៃសេដ្ឋកិច្ចទទួលបានលទ្ធផលល្អប្រសើរ គឺ កសិកម្មកើន ៤,៣% ឧស្សាហកម្មកើន ៩,២% និង សេវាកម្ម (គិតទាំងទេសចរណ៍ និងសំណង់) កើន ៨,១%។ ក្នុងវិស័យទាំងនេះក៏ចាប់ឃើញមានសញ្ញានៃពិពិធកម្មឈានទៅផលិតទំនិញមានតម្លៃបន្ថែមខ្ពស់ និង ទៅកាន់វិស័យថ្មីៗ ដូចជា រ៉ែ និងប្រេងកាត ជាដើម។

និន្នាការកំណើនខ្ពស់ និងចម្រុះមុខនេះ ទទួលបានពីកត្តាមួយចំនួនដែលមានជាសំខាន់ ការពង្រឹងសមាហរណកម្មក្នុងតំបន់ ការប្រកាសអនុវត្តប្រកបដោយប្រសិទ្ធភាពនូវក្របខ័ណ្ឌគោលនយោបាយជាតិ និងតាមវិស័យ និងការផ្លាស់ប្តូរលក្ខខណ្ឌពាណិជ្ជកម្មអន្តរជាតិដែលអំណោយផលដល់សេដ្ឋកិច្ចកម្ពុជា។

វិស័យកសិកម្ម ទទួលបានអត្ថប្រយោជន៍ពីគំនិតផ្តួចផ្តើមពាណិជ្ជកម្ម "ទំនិញគ្រប់មុខក្រៅពីអាវុធ" របស់សហភាពអឺរ៉ុប និងកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការជំរុញពាណិជ្ជកម្មដំណាំស្រូវ និងកៅស៊ូ។ ជាលទ្ធផល ការនាំចេញស្រូវ កើនដល់ ១៨០.០០០តោន ក្នុងឆ្នាំ២០១១ និង ២០៧.១៦៨តោន ក្នុងឆ្នាំ២០១២ ហើយក្នុងនោះមានជាង ៨០% បាននាំចេញទៅអឺរ៉ុប។ ការនាំចេញកៅស៊ូ កើន ៣០% ពី ៤៦.១៦៨តោន ក្នុងឆ្នាំ២០១១ ដល់ ៦០.០៣២តោន ក្នុងឆ្នាំ២០១២។ ប៉ុន្តែ តម្លៃសរុបនៃការនាំចេញកៅស៊ូ ថយចុះ ១០,៦% ក្នុងឆ្នាំ២០១២ ដោយសារការធ្លាក់ចុះថ្លៃកៅស៊ូលើពិភពលោក ហើយចំណុចនេះបញ្ជាក់ពីភាពត្រឹមត្រូវនៃគោលនយោបាយរបស់រដ្ឋាភិបាល ដែលផ្តោតខ្លាំងលើពិពិធកម្មមុខទំនិញ។

មានភស្តុតាងបង្ហាញថា ពិពិធកម្មកសិកម្មមួយចំនួនកំពុងកើតមានឡើង។ តួយ៉ាង កំណែទម្រង់ឡូត៍នេសាទ បានជួយឲ្យផលនេសាទកើន ៦,៧% ក្នុងឆ្នាំ២០១២។

ឧស្សាហកម្មផលិតជាពិសេសផ្នែកកាត់ដេរនិងស្បែកជើងនៅតែមានចំណែកចម្បងនៅក្នុងចំណូលបានពីការនាំចេញ។ ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងផលិតផលវាយនភ័ណ្ឌដទៃទៀត រួមចំណែកជាង ៩០% ក្នុងការនាំចេញសរុប ដោយមានកំណើនប្រចាំឆ្នាំជាមធ្យម ១៨,១% ពីឆ្នាំ២០០០ ដល់ ២០១២ លើកលែងតែក្នុងពេលមានវិបត្តិឆ្នាំ២០០៩ ដែលវាបានធ្លាក់ចុះអស់ ១៤,៣%។ នៅឆ្នាំ២០១២ ការនាំចេញសម្លៀកបំពាក់ទៅសហភាពអឺរ៉ុប កើនពី ២៣% ដល់ ៣០% នៃការនាំចេញសរុប ដែលជាលទ្ធផលនៃគំនិតផ្តួចផ្តើមពាណិជ្ជកម្ម "ទំនិញគ្រប់មុខក្រៅពីអាវុធ" នោះដែរ។

កំណើនក្នុងវិស័យសេវាកម្ម ស្ទុះឡើងក្នុងឆ្នាំ២០១២ ដោយសារចំនួនភ្ញៀវទេសចរកើន ២៤,៤% ធៀបនឹងមួយឆ្នាំមុន ដល់ជាង ៣,៥លាននាក់។ វិស័យទេសចរណ៍ ប្រើប្រាស់ពលករដោយផ្ទាល់ ៣៥០.០០០នាក់ និងជាប្រភពចំណូលបន្ថែមសម្រាប់ពលករជាច្រើននាក់ទៀត។ នៅឆ្នាំ២០១២ វិស័យនេះ រកចំណូលបានប្រមាណ ២ពាន់លានដុល្លារ ឲ្យសេដ្ឋកិច្ចកម្ពុជា។ មានសញ្ញាបង្ហាញថា វិស័យទេសចរណ៍ កំពុងមានធ្វើពិពិធកម្ម តាមការដាក់បញ្ចូលឆ្នេរសមុទ្រ និងអេកូទេសចរណ៍ ក្នុងនេះការអភិវឌ្ឍកោះមួយចំនួននៅកម្ពុជា បានផ្តល់ឱកាសថ្មីៗ និងទាក់ទាញភ្ញៀវទេសចរលំដាប់ខ្ពស់ៗឲ្យមកកម្ពុជាកាន់តែច្រើនឡើង។ បន្ទាប់ពីបានរួមចុះយ៉ាងខ្លាំងក្នុងអំឡុងវិបត្តិហិរញ្ញវត្ថុ វិស័យ

តារាង ១៖ សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ

| (គិតជា %នៃ ផសស បើសិនគ្មានការបញ្ជាក់ផ្សេង) | 2009 | 2010 | 2011 | 2012p |
|---|---|---|---|---|
| ផសស ចារឹក (គិតជា លានដុល្លារ) | 10400 | 11634 | 12937 | 14231 |
| ផសស ពិត (កំណើនជា %) | 0.1 | 6.0 | 7.1 | 7.3 |
| - កសិកម្ម (ចំណែកក្នុង ផសស) | 33.5 | 33.9 | 34.6 | 36.8 |
| - ឧស្សាហកម្ម (ចំណែកក្នុង ផសស) | 21.7 | 21.9 | 22.1 | 21.9 |
| - សេវាកម្ម (ចំណែកក្នុង ផសស) | 38.8 | 38.3 | 37.5 | 35.9 |
| ផសស ក្នុងមនុស្សម្នាក់ (គិតជា ដុល្លារ) | 753 | 830 | 911 | 990 |
| អតិផរណា (គិតជា %) | -0.6 | 4.0 | 5.5 | 2.9 |
| ប្រាក់សន្សំរបស់ជាតិ (% នៃ ផសស) | 21.1 | 24.7 | 24.4 | 23.7 |
| ប្រាក់ចំណូលក្នុងស្រុក | 11.9 | 13.2 | 13.2 | 13.7 |
| ចំណាយចរិកា | 20.5 | 21.3 | 20.7 | 19.0 |
| ឱនភាពសរុប | -6.4 | -8.7 | -7.3 | -5.3 |
| ចំណាយលើវិនិយោគ | 9.1 | 10.3 | 9.3 | 7.3 |
| វិនិយោគក្នុងស្រុក | 13.4 | 14.1 | 13.7 | 13.3 |
| វិនិយោគឯកជន | 16.6 | 18.2 | 16.8 | 16.7 |

ប្រភពៈ បណ្ឌិត ហង់ ជួន ណារ៉ុន សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា

## រូបភាព ១៖ ការប្រៀបធៀបសូចនាករសុខភាពកម្ពុជាជាមួយប្រទេសនានា




ប្រភព: បណ្ឌិត ស្រ៊ីនីវ៉ាសា ម៉ាឌូ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា

សំណង់កំពុងបន្តរើបឡើងវិញ ដោយមានសញ្ញាបង្ហាញពីលទ្ធផលរឹងមាំក្នុងឆ្នាំ២០១២ ទោះបីមិនទាន់មានតួលេខច្បាស់លាស់ក្តី។

វិស័យនានាកំពុងរីកលូតលាស់នៅលើគ្រឹះដ៏រឹងមាំនៃ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចយ៉ាងត្រឹមត្រូវ។ ទោះបីមានកំណើនសេដ្ឋកិច្ចខ្ពស់ក្តី ក៏អតិផរណាក្នុងឆ្នាំ២០១២ ស្ថិតក្នុងអត្រា ២,៧% ដោយធ្លាក់ចុះពីកម្រិតខ្ពស់បំផុត ១៩,៥% កាលពីឆ្នាំ២០០៨ ហើយតាមការព្យាករណ៍អតិផរណាក្នុងឆ្នាំ២០១៣ មានកម្រិត ៣,០%។ សូចនាករសំខាន់ៗផ្សេងទៀត ក៏បង្ហាញពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ចល្អក្នុងឆ្នាំ២០១២ ព្រមទាំងស្ថិរភាពសម្រាប់ឆ្នាំ២០១៣ ដូចជា៖ អត្រាប្តូរប្រាក់នៅថេរ អតិរេកថវិកាដល់ ១,៩% នៃ ផសស ឱនភាពគណនីចរន្តរួមតូច ជញ្ជីងទូទាត់មានអតិរេក ហើយ ធនបំរុងជារូបិយវត្ថុអន្តរជាតិកើនដល់ ៣,៤ ពាន់លានដុល្លារ (តារាង ១)។ ស្ថិរភាពនេះ នាំឲ្យ FDI កើនឡើងដល់កម្រិតមុនពេលមានវិបត្តិ ហើយអាចឲ្យរដ្ឋាភិបាលដកចេញវិញបាននូវកញ្ចប់ថវិកាជំរុញសេដ្ឋកិច្ច ។

ការប្រមូលចំណូល កំពុងបោះជំហានធំៗទៅមុខ នៅពេលរដ្ឋាភិបាលព្យាយាមបង្កើនធនធានសម្រាប់វិស័យសុខាភិបាល អប់រំ និងហេដ្ឋារចនាសម្ព័ន្ធ។ ចំណូលពន្ធ រំពឹងកើនឡើងពី ១០,៩% នៃ ផសស ក្នុងឆ្នាំ២០១១ ដល់ ១១,៤% នៃ ផសស ក្នុងឆ្នាំ២០១២។ ចំណូលបានពីអគ្គនាយកដ្ឋានពន្ធដារ មានកំណើនប៉ាន់ស្មាន ២៧% ក្នុងឆ្នាំ២០១២ ដល់ ២៥០១ពាន់លានរៀល (៦២៥លានដុល្លារ)។

វិស័យធនាគារនៅកម្ពុជា កាន់តែទំនើបឡើង ដោយមាន ៣២ ធនាគារពាណិជ្ជ, ៧ ធនាគារឯកទេស និង ៣៤ ស្ថាប័នមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណ កំពុងដំណើរការ គិតត្រឹមចុងឆ្នាំ២០១២។ ប្រាក់បញ្ញើ កើន ២៦,២% ពី ៤,៩ពាន់លានដុល្លារក្នុងឆ្នាំ២០១១ ដល់ ៦,២ពាន់លានដុល្លារក្នុងឆ្នាំ២០១២ ហើយឥណទានដល់វិស័យឯកជន កើន ៣៥,៤% ដល់ ៥,៩ពាន់លានដុល្លារ។ ប្រាក់បញ្ញើមីក្រូហិរញ្ញវត្ថុ ក៏កើនតាមអត្រាលេខពីរខ្ទង់ដែរ ដល់ ២៧៣,៩លានដុល្លារ រីឯកម្ចីបានផ្តល់សរុប កើន ៣៧,៩% ដល់ ៨៨៥,៨លានដុល្លារ។

## កំណើនសេដ្ឋកិច្ចលឿន ប៉ុន្តែមិនសម្រាប់គ្រប់គ្នា

នៅកម្ពុជា សូចនាករនៃការអភិវឌ្ឍសម្រាប់គ្រប់គ្នាមានការកែលំអយឺតជាង លទ្ធផលសេដ្ឋកិច្ចដ៏គួរឲ្យកោតសរសើរនេះ។ ការស្រាវជ្រាវនាពេលថ្មីៗបង្ហាញថា កម្ពុជាមាន សូចនាករចំណាយប្រើប្រាស់ (ចំណូល) អំណោយផលបង្គួរដល់អ្នកក្រ ប៉ុន្តែនៅយឺតយ៉ាវក្នុងការញ៉ាំងឲ្យចំណាយមិនប្រើប្រាស់(មិនមែនចំណូល) មានលក្ខណៈសម្រាប់គ្រប់គ្នា ជាពិសេស ផ្នែកអប់រំ និងថែទាំសុខភាព។

វិស័យអប់រំ មានការរីកចម្រើនដោយផ្នែក។ ការអប់រំនៅកម្រិតបឋមរីកលូតលាស់ខ្លាំង ប៉ុន្តែនៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា នៅមានបញ្ហាចោទច្រើន។ បញ្ហាទី១ទាក់ទងនឹងលទ្ធភាពទទួលបានការសិក្សា៖ គ្រួសារជាច្រើន ជាពិសេសអ្នកក្រីក្រ មិនមានលទ្ធភាពបង់ថ្លៃសិក្សានៅកម្រិតមធ្យមសិក្សា និងកម្រិតសាកលវិទ្យាល័យឡើយ។ ទី២ ស្ថាប័នអប់រំថ្នាក់ខ្ពស់ មានការត្រួតពិនិត្យទន់ខ្សោយ ហើយមានស្ថាប័នជាច្រើនផ្តល់ការសិក្សាមានគុណភាពទាប និងសញ្ញាប័ត្រគ្មានតម្លៃ បើធៀបនឹងចំណាយដ៏ខ្ពស់ដែលគ្រួសារត្រូវបង់។ ទី៣ រចនាសម្ព័ន្ធបច្ចុប្បន្ននៃឧត្តមសិក្សានៅកម្ពុជា មិនបានផ្តល់នូវកម្លាំងពលកម្មមានជំនាញស៊ីគ្នានឹងតម្រូវការទីផ្សារការងារឡើយ។ តួយ៉ាង វិស័យនេះមានទំនោរផ្តល់ជំនាញសម្រាប់ការងារក្នុងការិយាល័យ ដូចជាខាង បច្ចេកវិទ្យាព័ត៌មាន និងការគ្រប់គ្រងអាជីវកម្ម ជាដើម ទោះបីការងារខាង ផ្នែកកម្មន្តសាលកម្ម មានច្រើនសន្ធឹកជាងក្តី។

ប្រព័ន្ធថែទាំសុខភាពនៅកម្ពុជា មិនទាន់គ្របដណ្តប់បានគ្រប់គ្រាន់ដល់គ្រួសារក្រីក្រទេ និងជាឧបសគ្គមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចសម្រាប់គ្រប់គ្នា។ ប្រទេសដែលផ្តល់សេវាសង្គមបានល្អ តែងមានផលិតភាពកម្លាំងពលកម្ម និងកំណើនសេដ្ឋកិច្ចខ្ពស់ជាង ព្រោះកាលណាប្រជាជនមានសុខភាពល្អ ការបង្វែរប្រាក់ចេញពីសកម្មភាពសហគ្រាស ទៅចំណាយលើការថែទាំសុខភាព ក៏មានតិចជាងដែរ។ កម្លាំងជំរុញនេះកើតមានដូចគ្នាសម្រាប់ គ្រួសារក្រីក្រដែលតែងមានធនធានតិច ដើម្បីដោះស្រាយការចំណាយបន្ថែមផុសចេញពីតម្រូវការថែទាំសុខភាព។ កម្ពុជានៅដើរក្រោយប្រទេសឯទៀតក្នុងតំបន់ ក្នុងទិដ្ឋភាពជាច្រើននៃការថែទាំសុខភាព (រូបភាព ១)។

បញ្ហាចម្រូងចម្រាស់មួយ រាំងស្ទះការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចសម្រាប់គ្រប់គ្នា គឺការគ្រប់គ្រងដី និងកម្មសិទ្ធិដីធ្លី ជាពិសេសនៅតាមកន្លែងដែលម្ចាស់ដីតូចៗមានទំនាស់ជាមួយ អ្នកទទួលបានសម្បទានដីសេដ្ឋកិច្ច។ ទំនាស់ដីធ្លីប្រភេទនេះ មានការផ្សព្វផ្សាយជាសាធារណៈជាច្រើនករណីរួចមកហើយ។ រដ្ឋាភិបាល បានទទួលស្គាល់ពីតម្រូវការគោលនយោបាយដើម្បីរក្សាតុល្យភាពរវាង តម្រូវការខាងសេដ្ឋកិច្ចនូវសម្បទានដីសេដ្ឋកិច្ច នៅក្នុងដំណើរផ្លាស់ប្តូរទៅធ្វើកសិកម្មជាទ្រង់ទ្រាយពាណិជ្ជកម្ម និងកិច្ចការពារទ្រព្យសម្បត្តិរបស់ម្ចាស់ដីតូចៗក្នុងលក្ខណៈមួយដែលជួយជំរុញដល់ការអភិវឌ្ឍសម្រាប់គ្រប់គ្នាក្នុងសង្គម។

ថ្មីៗនេះ រដ្ឋាភិបាលបានដាក់បញ្ជាឲ្យសើរើពិនិត្យឡើងវិញនូវដំណើរការបែងចែកសម្បទានដីសេដ្ឋកិច្ច ហើយសម្បទានដីសេដ្ឋកិច្ចជាច្រើនដែលគេរកឃើញថាបានបំពានទៅលើលក្ខខណ្ឌនៃកិច្ចសន្យា ក៏ត្រូវបានលុបចោល។ រដ្ឋាភិបាលត្រូវធានាថា សម្បទានដីសេដ្ឋកិច្ចមិនមានផលប៉ះពាល់អវិជ្ជមានទៅលើចីរភាពសង្គម និងបរិស្ថាន ជាពិសេសសម្រាប់សហគមន៍ ដែលរងផលប៉ះពាល់ពីសកម្មភាពនៃសម្បទានទាំងនោះ។ សេចក្តីសម្រេចស្តីពី ការអនុវត្ត ការវាយតម្លៃសព្វគ្រប់នូវផលប៉ះពាល់ខាងបរិស្ថាន និងផែនការពិនិត្យតាមដាននិងវាយតម្លៃនានា (M&E) ត្រូវតែអនុវត្តឲ្យបានតឹងរឹងមុនពេលចេញអាជ្ញាប័ណ្ណឲ្យគម្រោងសម្បទានដីសេដ្ឋកិច្ច។

កម្មវិធីចុះបញ្ជីដីធ្លីថ្នាក់ជាតិ ក៏សំដៅបង្កើនសន្តិសុខក្នុងការកាន់កាប់ដីតាមគ្រួសារនៅទូទាំងប្រទេសដែរ។ តាមការបង្គាប់បញ្ជារបស់សម្តេចនាយករដ្ឋមន្ត្រី គម្រោងនេះត្រូវបានពង្រីកថែម ដើម្បីពន្លឿនការចេញប័ណ្ណកម្មសិទ្ធិដីទៅឲ្យគ្រួសារមានដីតូចៗនៅជនបទ ហើយបង្កើនសន្តិសុខក្នុងការកាន់កាប់ដី។ កិច្ចប្រឹងប្រែងទាំងនេះត្រូវរក្សាឲ្យមាន

ចីរភាព បើសិនចង់សម្រេចបាននូវ សន្តិសុខដីធ្លីជាសាកលដែលជាមូលដ្ឋានគ្រឹះនៃកំណើនសម្រាប់គ្រប់គ្នា។

ការមិនបានដោះស្រាយបញ្ហាដ៏ចម្បងនៃ កំណើនសេដ្ឋកិច្ចសង្គមកិច្ចសម្រាប់គ្រប់គ្នា អាចបង្កការខូចខាតដល់សមិទ្ធផលដែលកម្ពុជាសម្រេចបានដោយលំបាកក្នុងពីរទសវត្សរ៍កន្លងមកនេះ។ មានការមូលមតិថា វិសមភាពកម្រិតខ្ពស់និងរ៉ាំរ៉ៃក្នុងប្រាក់ចំណូល និងជាពិសេសក្នុងឱកាសរកចំណូល នឹងបង្កអន្តរាយដល់កំណើនមានចីរភាព។ ធ្ងន់ធ្ងរជាងនេះទៀត វិសមភាពអាចបំផ្លាញភាពរួបរួមគ្នាល្អ និងជុតបញ្ឆេះការរើករវក្នុងសង្គម។ ដូច្នេះនៅពេលកំពុងសប្បាយរីករាយនឹងផ្លែផ្កានៃកំណើនសេដ្ឋកិច្ចដ៏ខ្ពស់នេះ កម្ពុជាត្រូវតែប្រុងប្រយ័ត្នខ្លាំងចំពោះកម្រិតនៃវិសមភាពក្នុងសង្គម ហើយធានាថា វិបុលភាពបានពីកំណើនត្រូវបានចែកចាយទៅដល់គ្រប់ផ្នែកនៃសង្គម។

## ការឈានទៅកាន់ ឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យម

រចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាមានការផ្លាស់ប្តូរ នៅពេលកម្ពុជាកំពុងឈានទៅកាន់ឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យម។ ក្នុងនេះក៏មានក្តីបារម្ភពីបាតុភូតមួយហៅថា "អន្ទាក់នៃភាពជាប្រទេសមានចំណូលមធ្យម" ដែលជា ការអភិវឌ្ឍសេដ្ឋកិច្ចត្រូវជាប់គាំង ដោយសារកំណើនផសស គិតក្នុងមនុស្សម្នាក់ បានកាត់បន្ថយឥទ្ធិពលនៃឧត្តមភាពប្រៀបធៀបដែលជាកត្តាជំរុញដល់កំណើនខ្ពស់ក្នុងអតីតកាល។ ប្រសិនបើមិនបានទប់ទល់ក្នុងពេលនេះទេ ឥទ្ធិពលនេះវាអាចបញ្ចប់នូវកំណើនលឿននៃសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន។

អ្នកធ្វើគោលនយោបាយបានទទួលស្គាល់ថា ឧត្តមភាពប្រៀបធៀបរបស់កម្ពុជានឹងផ្លាស់ប្តូរនៅពេលសេដ្ឋកិច្ចរីកលូតលាស់។ នាពេលបច្ចុប្បន្ន អត្ថប្រយោជន៍ចម្បងមួយដែលទាក់ទាញវិនិយោគ និងធ្វើឲ្យការនាំចេញមានលក្ខណៈប្រកួតប្រជែង គឺ ពលកម្មមានតម្លៃទាប ប៉ុន្តែអត្ថប្រយោជន៍នេះនឹងត្រូវបាត់បង់នៅពេលដែល ផសស គិតក្នុងមនុស្សម្នាក់កើនខ្ពស់ឡើង។ ដូច្នេះ កម្លាំងពលកម្មត្រូវតែមានជំនាញសមស្របដើម្បីធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចឲ្យមានលក្ខណៈកាន់តែជឿនលឿន និងមានតម្លៃបន្ថែមខ្ពស់ ទាំងផ្នែកឧស្សាហកម្ម កសិកម្ម និងសេវាកម្ម។

រដ្ឋាភិបាល បាននិងកំពុងជំរុញ កម្មវិធីអប់រំបណ្តុះបណ្តាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ដើម្បីបង្កើនជំនាញនៃកម្លាំងពលកម្មនៅកម្ពុជា។ ការពង្រីកកម្មវិធីនេះ ជាការចាំបាច់បំផុតក្នុងពេលឥឡូវដើម្បីត្រៀមរៀបចំសម្រាប់ការចូលក្នុង សហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥ និងដើម្បីគេចផុតពីអន្ទាក់គ្រោះថ្នាក់នៃភាពជាប្រទេសមានចំណូលមធ្យម។ ការពង្រីកកម្មវិធីនេះ ត្រូវមានយន្តការផ្នែកស្ថាប័នមួយដែលជំរុញឲ្យរដ្ឋាភិបាល ស្ថាប័នអប់រំថ្នាក់ខ្ពស់ និងវិស័យឯកជន ធ្វើការរួមគ្នាសំដៅបង្កើតកម្មវិធីសិក្សាផ្សេងៗ ដែលពោរពេញដោយថាមពល និងមានភាពបត់បែនល្អ ដើម្បីដើរឲ្យទាន់តាមលក្ខខណ្ឌសេដ្ឋកិច្ចដែលកំពុងផ្លាស់ប្តូរយ៉ាងលឿន។

រដ្ឋាភិបាលត្រូវប្រឹងប្រែងពង្រឹងវិស័យហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់សហគ្រិនភាព និងពិពិធកម្មសេដ្ឋកិច្ច។ ដូចគ្នានឹងប្រទេសដទៃទៀតដែលស្ថិតក្នុងដំណាក់កាលស្រដៀងគ្នានៃការអភិវឌ្ឍដែរ ធនាគារនៅកម្ពុជាតែងផ្តល់ឥណទានទៅឲ្យក្រុមហ៊ុនធំៗ ជាជាងទៅឲ្យសហគ្រាសធុនតូចនិងមធ្យម។ ឥណទានទៅឲ្យផ្នែកជំរុញកំណើនទៅអនាគតទាំងនេះ ត្រូវតែពង្រីកបន្ថែម ប៉ុន្តែត្រូវមានច្បាប់គ្រប់គ្រង និងការត្រួតពិនិត្យត្រឹមត្រូវ ដើម្បីកាត់បន្ថយហានិភ័យ។ បញ្ហាផ្តល់ឥណទាន គួរដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រធំទូលាយមួយ ដើម្បីឲ្យសេដ្ឋកិច្ចកាន់តែមានលក្ខណៈរៀបរយ ហើយជួយបង្កើនទាំងវិនិយោគ និងការប្រមូលចំណូល។ នៅក្នុងរយៈពេលវែង ការធ្វើបដិរូបនីយកម្មក្នុងសេដ្ឋកិច្ច សំខាន់ខ្លាំងណាស់ ដើម្បីពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុថែមទៀត។

អ្នកធ្វើគោលនយោបាយ ក៏ត្រូវធ្វើសកម្មភាពដើម្បីទាញយកផលប្រយោជន៍ពី ស្ថានភាពប្រទេសចិនដែលក្លាយជាកត្តាដ៏សំខាន់ជំរុញកំណើនសេដ្ឋកិច្ចពិភពលោក។ ការវិនិយោគ និងពាណិជ្ជកម្មក្នុងតំបន់កំពុងផ្តល់ឱកាសថ្មីៗកាន់តែច្រើន សម្រាប់កំណើនក្នុងវិស័យជាប្រពៃណីក៏ដូចជាក្នុងផ្នែកថ្មីៗ មានជាអាទិ៍ ការយករ៉ែ វារីអគ្គិសនី ដំណាំលក់យកប្រាក់ និងប្រេងកាត។ ដើម្បីក្តាប់យកឱកាសផ្តល់ដោយកំណើនរបស់ប្រទេសចិននេះ កម្ពុជាត្រូវតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធរឹង និងទន់របស់ខ្លួន ដោយមានទំនួលខុសត្រូវខ្ពស់ចំពោះផ្នែកបរិស្ថាន និងសង្គមនៅក្នុងបរិបទសាកលបច្ចុប្បន្ននៃការស្វែងរកកំណើនសម្រាប់គ្រប់គ្នា និងមិនប៉ះពាល់ដល់បរិស្ថាន។

អាស៊ានមានកម្លាំងរឹងមាំអាចជួយបង្កើនអំណាចចរចារបស់កម្ពុជានិងធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាទទួលបានអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀមអនុគ្រោះផ្នែកពាណិជ្ជកម្មជាមួយប្រទេសចិន និងបណ្តាប្រទេសមានសេដ្ឋកិច្ចកំពុងស្ទុះឡើងនៅតំបន់អាស៊ី។ ក្នុងឋានៈជាប្រធានអាស៊ាននៅឆ្នាំ២០១២ កម្ពុជាបានលើកទឹកចិត្តឲ្យប្រទេសជាសមាជិកដាក់បញ្ចូលនូវកំណែទម្រង់ចាំបាច់នានា ដើម្បីជំរុញការចូលទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥។ ប៉ុន្តែក៏មានគ្រោះថ្នាក់មួយដែរ គឺលទ្ធភាពកំណត់គោលនយោបាយរបស់កម្ពុជា អាចនឹងត្រូវកាត់បន្ថយ ដោយសារកាតព្វកិច្ចផ្សេងៗចំពោះអាស៊ាន។ នេះជាបញ្ហាសំខាន់មួយសម្រាប់កម្ពុជា ដែលមានវិស័យជាច្រើនដើរយឺតជាងប្រទេសជិតខាង ហើយត្រូវមានសកម្មភាពខាងគោលនយោបាយច្បាស់លាស់និងឥតរារែក។

ចំណុចសំខាន់បំផុតមួយទៀតគឺ ក្របខ័ណ្ឌគោលនយោបាយនានាត្រូវជួយសម្រួលដល់កំណើនលំហូរវិនិយោគបរទេសនៅក្នុងតំបន់ ហើយក្នុងនេះ ការកែលំអបរិយាកាសអាជីវកម្មនៅកម្ពុជា ជាលក្ខខណ្ឌមួយត្រូវបំពេញឲ្យបានជាមុន។ ឧបសគ្គធំបំផុតក្នុងការបង្កើតបរិយាកាសអំណោយផលដល់ដំណើរការអាជីវកម្ម គឺអំពើពុករលួយ ជាពិសេសនៅពេលវារាំងស្ទះដល់ការដោះស្រាយទំនាស់ និងការពង្រឹងអនុវត្តន៍កិច្ចសន្យា។ ក្នុងរយៈពេលវែង វិនិយោគបរទេសចម្រុះមុខ ទាមទារនូវបរិយាកាសស្ថាប័នមួយដែលលើកកម្ពស់កម្មសិទ្ធិបញ្ញា និងការបែងចែកព័ត៌មានទីផ្សារឲ្យបានស្មើភាព។ សមត្ថភាពស្ថាប័នមានស្រាប់ គឺអាចធ្វើការកែសម្រួលបន្ថែមដើម្បីបំពេញតម្រូវការនេះ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**
☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥ ២៣) ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ 🖷 (៨៥៥ ២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh, website: www.cdri.org.kh